# អារម្ភកថា

មិត្តអ្នកអានជាទីគោរព!

យើងតែងតែនិយាយអំពី**សង្គមល្អប្រកបដោយប្រជាធិបតេយ្យ** ។ យើងត្រូវផ្តោតបន្ថែមទៅលើការយល់ដឹង និងការអនុវត្តឱ្យចេញបានជារូបរាងជាក់ស្តែងទោះវាជារឿងលំបាក និងស្មុគស្មាញក៏ដោយ ។ សង្គមល្អអាស្រ័យ និងអភិបាលកិច្ចល្អដែលជាការទទួលខុលត្រូវរួមទាំងពលរដ្ឋ និងរដ្ឋរួមគ្នា ។

មនុស្សភាគច្រើនតែងតែយល់ថា អភិបាលកិច្ចល្អ និងប្រជាធិបតេយ្យ គឺនៅត្រឹមតែអំពីនយោបាយ និងការគ្រប់គ្រងប៉ុណ្ណោះ ។ នេះមិនមែនជាទស្សនៈរបស់យើងទេ ។ តាមពិត**សង្គមល្អ**ទាល់តែមានភ្ជាប់ ប្រជាធិបតេយ្យ ដែលជាមធ្យោបាយនៃជីវិត ឬ មានពាក្យម្យ៉ាងទៀតថា **សង្គមល្អ** ទាល់តែមានការចូលរួមរបស់ប្រជាពលរដ្ឋដែលជាមធ្យោបាយសំរាប់យើងប្រព្រិត្តក្នុងជីវិតរស់នៅប្រចាំថ្ងៃ ។ **ប្រជាធិបតេយ្យមានន័យថា អំណាចទាំងអស់ជាកម្មសិទ្ធិរបស់ឱ្យពលរដ្ឋ ដែលនឹងប្រើប្រាស់អធិបតេយ្យភាពរបស់ខ្លួន ស្របតាមរដ្ឋធម្មនុញ្ញ** ។ ប្រជាធិបតេយ្យ គឺឈរលើការទទួលខុសត្រូវ និងមានគណនេយ្យភាពផ្ទាល់ខ្លួន ភាពត្រឹមត្រូវ តម្លាភាព និងមិនអាត្មានិយម និងជាសំខាន់គឺការចូលរួមក្នុងកិច្ចការសម្រេចចិត្តក្នុងការងាររដ្ឋបាលសាធារណៈ ។ យើងជឿថាយើងអាចកសាងសង្គមមួយល្អ នៅគ្រប់ក៏រិត បើយើងទាំងអស់គ្នាអនុវត្តប្រជាធិបតេយ្យដោយប្រើជំនាញទំនាក់ទំនងល្អ ដើម្បីធ្វើការសំរេចចិត្ត ការសហការ ការចូលរួម និងការដោះស្រាយទំនាស់ដោយសន្តិវិធី ។

កូនសៀវភៅ **យើងកសាងសង្គមល្អនៅកម្ពុជា** នឹងនាំមកនូវរូបភាព ខ្លឹមសារសំខាន់ៗ និង មធ្យោបាយដែលនាំមកនូវ **សង្គមល្អ** មកបង្ហាញ ដើម្បីធ្វើឱ្យមានការ

យល់ដឹងកាន់តែច្បាស់ និងរបៀបនៃការអនុវត្តន៍ ថាតើត្រូវធ្វើដូចម្តេចដើម្បីឱ្យក្លាយទៅជាមធ្យោបាយសំរាប់ប្រព្រឹត្តក្នុងជីវិតរស់នៅប្រចាំថ្ងៃ ។

កូនសៀវភៅនេះ នឹងបង្ហាញអ្នកអានឱ្យយល់នូវអ្វីជាសង្គមល្អ ។ សង្គមល្អទាល់តែមាន ការផ្តល់សេវាកម្មសាធារណៈបានល្អទាំងបរិមាណ គុណភាព និងប្រសិទ្ធភាពខ្ពស់ នេះជាមុខងារដែលភាគីមានកាតព្វកិច្ច( រដ្ឋ) ត្រូវអនុវត្ត ឱ្យបាន ។ជាបន្ថែមទៀតសង្គមល្អក៏ត្រូវមានយុត្តិធម៌ និងសិទ្ធិ ចេះចែករំលែក និងជួយយកអាសាគ្នាទៅវិញទៅមក ។ ដើម្បីអនុវត្តសេវាកម្មសាធារណៈបានល្អទាល់តែមានអភិបាលកិច្ចល្អ ។ ដើម្បីមានអភិបាលកិច្ចល្អទាល់តែមានគណនេយ្យភាពសង្គម ដែលជាឧបករណ៏សំរាប់តាមដាន វាស់វែង ត្រួតពិនិត្យលើការផ្តល់សេវាកម្មសាធារណៈបាន ។ ឯពលរដ្ឋជាភាគីទាមទារ ចេះក្បៀងគរប្រមែប្រមូលគ្នា ចងក្រងជាក្រុមឱ្យមានកំលាំងរឹងមាំ ដើម្បីធ្វើការតស៊ូមតិ ទាមទារ ជជែកចរចា ឱ្យ ភាគីមានកាតព្វកិច្ច( រដ្ឋ) ទទួលយក និងអនុវត្តឱ្យបាន ។ នេះជាការអនុវត្តនូវលទ្ធិ ប្រជាធិបតេយ្យក្នុងសង្គមល្អ ។

យើងសង្ឃឹមថា កូនសៀវភៅនេះជាការណែនាំសង្ខេបមួយសំរាប់អ្នកអាន ដើម្បីជាប្រជុំគំនិតសំរាប់ជាបច្ច័យក្នុងការត្រិះរិះពិចារណាផង និងជាមធ្យោបាយសំរាប់អនុវត្តក្នុងអង្គភាព នៅតាមមូលដ្ឋាន និងក្នុងជីវភាពរស់នៅប្រចាំថ្ងៃក្នុងគ្រួសារ ព្រោះសង្គមកម្ពុជាកំពុងតែធ្វើដំណើរ ទៅកាន់សង្គមល្អប្រកប ដោយអភិបាល កិច្ចល្អ តាមការអនុវត្ត លទ្ធិប្រជាធិបតេយ្យហើយ។

*ក្រុមរៀបរៀង*

*អង្គការសីលការ*

# មាតិកា

ទំព័រ


១ - សង្គមល្អ ១

២ - អភិបាលកិច្ចល្អ ៧

៣ - គណនេយ្យភាពសង្គម ១៧


តើធ្វើដូចម្តេចដើម្បី ឱ្យមានអភិបាលកិច្ចល្អ?
តើពលរដ្ឋ និង រដ្ឋមានភារកិច្ច ធ្វើអ្វីខ្លះក្នុងសង្គមល្អ?
អ្វីទៅជា អភិបាលកិច្ចល្អ?
អ្វីទៅហៅថា សង្គមល្អ?
អ្វីទៅជា គណនេយ្យភាពសង្គម?

# ជំពូក ១

# សង្គមល្អ



# អត្ថន័យនៃសង្គមល្អ...



# អត្ថន័យនៃសង្គមល្អ...








**ពលរដ្ឋត្រូវសកម្ម និងចូលរួមក្នុងសកម្មភាពសង្គម ៖**

១. ចូលរួមប្រជុំក្រុមប្រឹក្សា ឃុំ សង្កាត់, ទៅបោះឆ្នោត, ចូលរួមទាមទារដោយអហឹង្សា

២. ពលរដ្ឋសហការគ្នា ដឹកនាំគ្នា និងចងគ្នាជាក្រុមដើម្បីចរចាជាមួយរដ្ឋាភិបាល ។

**រដ្ឋាភិបាលត្រូវ ៖**

១. ជួយសំរួលឱ្យមានសេវាសង្គម និងជួយសំរួលឱ្យប្រជាពលរដ្ឋ អាចចូលរួមបាន ឧទា: អនុញ្ញាតិឱ្យតំណាងរបស់គាត់ចូលពិភាក្សា

២. ជំរុញឱ្យមានការចូលរួមតាមរយៈការចែករំលែកពត៌មាន

៣. ជាអ្នកផ្ដល់សេវាដែលមានប្រសិទ្ធភាព និងគុណភាពហើយទាន់ពេលវេលា និងមានតំលៃសមរម្យអាចទទួលយកបាន ។

# ភារៈកិច្ចរបស់ប្រជាពលរដ្ឋ និងរដ្ឋក្នុងសង្គមល្អ



## ការចូលរួមក្នុងសកម្មភាពសង្គមរបស់ពលរដ្ឋ និងការឆ្លើយតបរបស់រដ្ឋ



# ជំពូក ២

# អភិបាលកិច្ចល្អ

# អ្វីទៅជាអភិបាលកិច្ចល្អ ?



# ដើម្បីធ្វើឱ្យបានអភិបាលកិច្ចល្អ...



## "ទោសឯងមើលមិនឃើញ ទោសគេតូចសល់យល់ប៉ុនទាំងភ្នំ"



# ការអនុវត្តន៍ច្បាប់ដោយមិនលំអៀង




ការចាត់ចែងថវិកាជាតិ
៣០% ទៅវិស័យអប់រំ
៣០% សុខាភិបាល
២០% អភិ.ជនបទ
ប្រជាពលរដ្ឋបង់ពន្ធ
បង់ពន្ធ

## អ្វីទៅជាវិមជ្ឈការ?

**វិមជ្ឈការ** គឺជាការផ្ទេរអំណាច ធនធាន មុខងារ តួនាទី និងការសំរេចចិត្តពី រដ្ឋាភិបាល ថ្នាក់ជាតិទៅថ្នាក់ក្រោមជាតិ (ឧទាៈ ក្រុមប្រឹក្សាឃុំ មានសិទ្ធិរៀបចំ អនុម័ត និងអនុវត្ត ផែនការ អភិវឌ្ឍន៍ឃុំសង្កាត់របស់ខ្លួន) ។

## អ្វីទៅជាវិសហមជ្ឈការ?

**វិសហមជ្ឈការ** គឺជាការផ្ទេរអំណាច និងសេចក្ដីសំរេចចិត្តមួយចំនួន ពីរដ្ឋាភិបាលថ្នាក់ ជាតិ មកដល់ក្រោមជាតិ(ឧទាៈ ក្រសួងមហាផ្ទៃផ្ទេរ ការចុះបញ្ជីអត្រានុកូលដ្ឋានអោយ ក្រុមប្រឹក្សាឃុំ ជាអ្នកធ្វើ) ។

## វិមជ្ឈការមាន ៤ផ្នែក ដូចជាៈ

១- វិមជ្ឈការនយោបាយៈ ជាការផ្ទេរសិទ្ធិក្នុងការសំរេចចិត្តលើការ តាក់តែង និង អនុវត្តន៍គោលនយោបាយ ដល់រដ្ឋាភិបាលថ្នាក់ក្រោមជាតិ

២- វិមជ្ឈការហិរញ្ញវត្ថុៈ ការផ្ទេរសិទ្ធក្នុងការរកចំណូល និងការចាត់ចែងចំណាយ ដល់រដ្ឋាភិបាលថ្នាក់ក្រោមជាតិ

៣- វិមជ្ឈការរដ្ឋបាលៈ ជាការផ្ទេរការគ្រប់គ្រង ការទទួលខុសត្រូវ និងធនធាន ដើម្បីផ្ដល់សេវាដល់រដ្ឋាភិបាលថ្នាក់ក្រោមជាតិ

៤- វិមជ្ឈការសេដ្ឋកិច្ចៈ ការផ្ទេរទំនួលខុសត្រូវលើការផ្គត់ផ្គង់ ដែលធ្លាប់តែ គ្រប់គ្រងដោយរដ្ឋ ដល់រដ្ឋាភិបាលថ្នាក់ក្រោមជាតិ

# ការចែករំលែកភារៈកិច្ច




មជ្ឈការ



វិមជ្ឈការ

ការចែករំលែកភារកិច្ច នឹងបានផលទៅដល់គ្រប់គ្នា !
ដូចគ្នាទៅនឹងវិមជ្ឈការដល់ថ្នាក់ក្រោមជាតិ នឹងធ្វើឱ្យសេវាបានដល់ពលរដ្ឋ ។

## ពលរដ្ឋទទួលបានការឆ្លើយតប

**ទទួលខុសត្រូវក្នុងការអនុវត្តនីតួនាទី និងភារៈកិច្ច និងឆ្លើយតបទៅនឹងតំរូវការរបស់ពលរដ្ឋដោយស្មើភាព គ្មានការរើសអើងនិងតាមពេលវេលាសមរម្យ ។**



ប្រជាពលរដ្ឋ/សង្គមស៊ីវិល រដ្ឋាភិបាល និងវិស័យឯកជន

# យើងធ្វើឱ្យមានអភិបាលកិច្ចល្អ



# ជំពូក ៣

# គណនេយ្យភាពសង្គម

## អ្វីហៅថាគណនេយ្យភាពសង្គម?




**“គណនេយ្យភាពសង្គម”**

**សំដៅទៅលើសកម្មភាពជាក់លាក់ដែលធ្វើឡើងដើម្បី ញ៉ាំងឱ្យមន្ត្រីសាធារណៈ អ្នកនយោបាយ និង អ្នកផ្ដល់សេវា ទទួលខុសត្រូវចំពោះមុខប្រជាពលរដ្ឋពីទង្វើ និងការអនុវត្តន៍ការងាររបស់ខ្លួនក្នុងការផ្ដល់សេវា ការលើកកម្ពស់សុខុមាលភាពប្រជាពលរដ្ឋ និង ការការពារសិទ្ធិរបស់ប្រជាពលរដ្ឋ ។**

# ធ្វើអ្វីខ្លះដើម្បីឱ្យបានគណនេយ្យភាពសង្គម?



# វិធីសាស្ត្រខ្លះ ៖ ធ្វើផែនការដោយមានការចូលរួម



## វិធីសាស្ត្រខ្លះ : ការធ្វើសវនកម្មសង្គម



តើគណនេយ្យភាពសង្គមមានផលប្រយោជន៍អ្វីខ្លះ? ទៅដល់អ្នកណាខ្លះ?

១. វាធ្វើអោយរីកចំរើនដល់អភិបាលកិច្ចរបស់រដ្ឋ

២. ធ្វើអោយមានប្រសិទ្ធភាពខ្ពស់ដល់ការអភិវឌ្ឍន៍ប្រទេស

៣. ផ្តល់អំណាចដល់ប្រជាពលរដ្ឋតាមរយៈការចូលរួម ។

តើយើងធ្វើគណនេយ្យភាពសង្គមតាមវិធីណាខ្លះ ?

១. តាមរយៈការតាមដានលើការចំណាយថវិកាសាធារណៈ

២. ការចូលរួមធ្វើផែនការ

៣. សាវនកម្មសង្គម

៤. ការដោះស្រាយទំនាស់ដោយមានការចូលរួម

៥. បណ្ណ័រាយការណ៍ពតិមានរបស់ពលរដ្ឋ

៦.ធម្មនុញ្ញពលរដ្ឋ (គោលការណ៍កំណត់អំពីសិទ្ធរបស់ពលរដ្ឋនិងកាតព្វកិច្ចរបស់អ្នកផ្តល់សេវា (ឧទា: អាចជាតំលៃសេវាអគ្រានុកូលដ្ឋាន ការសន្យាធានារបស់រដ្ឋាភិបាលចំពោះពលរដ្ឋ)

៧. ។ល។



# ការចូលរួមទាមទារសេវារបស់ប្រជាពលរដ្ឋ



## សង្គមស៊ីវិលមានអ្នកណាខ្លះ ?

- អង្គការ
- សមាគម
- គណៈកម្មការភូមិ
- អង្គការមូលដ្ឋាន
- ប្រជាពលរដ្ឋ
- ។ល ។

## ភ្នាក់ងាររដ្ឋ/ស្ថាប័នសាធារណៈ :

- មន្ត្រីសាធារណៈ
- មន្ត្រីផ្តល់សេវាសាធារណៈ
- តំណាងរាស្ត្រ
- ក្រុមប្រឹក្សា
- គណៈអភិបាល
- ។ល ។

## ផ្នែកឯកជនមាន :

- ធុរៈកិច្ចគ្រប់ប្រភេទ
- សាជីវកម្មផ្សេងៗមាន អាជីវករ និងអ្នកជំនួញជាដើម

# សីលការ

**សីលការ** ជាអង្គការក្នុងស្រុកមួយ ដែលមិនមាននិន្នាការនយោបាយ ឬសាសនាណាមួយឡើយ ហើយបានចុះឈ្មោះជាមួយក្រសួងមហាផ្ទៃ នៃរាជរដ្ឋាភិបាលកម្ពុជា ក្នុងខែមករា ឆ្នាំ ១៩៩៧ ។ បេសកកម្មរបស់សីលការ គឺសម្របសម្រួលការអប់រំ ការអភិវឌ្ឍប្រជាជនកម្ពុជា ដើម្បីពង្រឹងអង្គភាព ស្ថាប័នរបស់គេ ដោយធ្វើការជាមួយបុគ្គលអង្គការ និងស្ថាប័ន ដែលយកចិត្តទុកដាក់យ៉ាងសកម្មក្នុងកិច្ចការ កសាងសមត្ថភាពកម្ពុជា ។ សីលការ បានរួមចំណែកក្នុងការអភិវឌ្ឍ និងអនុវត្តគម្រោងនានា ដែលបង្កើនទៅរកតម្លាភាព នៅក្នុងកិច្ចប្រឹងប្រែង ដើម្បីជំរុញការរីកចម្រើនក្នុងវិស័យ រៀបចំអង្គការ និងស្ថាប័ន ។ ក្រោមទស្សនៈវិស័យមួយ ដែលបានឃើញក្នុងប្រទេសកម្ពុជា ប្រកបដោយសន្តិភាព សីលការបានប្តូរផ្តាច់ជួយ ឱ្យមានការផ្លាស់ប្តូរសង្គមប្រកបដោយ ការស្ថាបនា ដែលអាចដោះស្រាយបាន ដោយមានប្រសិទ្ធភាព នូវសេចក្តីត្រូវការរួមរបស់សង្គមកម្ពុជាទាំងមូល ដើម្បីផ្តល់នូវសន្តិភាព ការជានាគ្នា ដែលជាជំហានសំខាន់ ដើម្បីបង្កើតនូវបរិយាកាស ជាអំណោយផលសម្រាប់ការអភិវឌ្ឍប្រកបដោយចេរភាព ។

## ទស្សនៈវិស័យ

ប្រជាពលរដ្ឋខ្មែរ រស់នៅក្នុងសង្គមមួយមានការអភិវឌ្ឍផ្នែកសេដ្ឋកិច្ច និងពហុនិយម ដែលឈរលើគុណតម្លៃនៃការសិក្សាបើកទូលាយ គោរពសិទ្ធិមនុស្ស សមភាពយេនឌ័រ និងមានជំនឿជាក់ពឹងខ្លួនឯង ។

## បេសកកម្ម

សីលការមានបេសកកម្មដើម្បី :

- រៀបចំស្ថាបនា ចាត់ចែង អភិវឌ្ឍ និងពង្រឹងអង្គការស្ថាប័ននានា
- ធ្វើការងារជាមួយបុគ្គល អង្គការ ស្ថាប័នយ៉ាងសកម្មដើម្បីលើកកម្ពស់សមធម៌ សមភាពយេនឌ័រក្នុង សង្គមខ្មែរ
- ចូលរួមក្នុងការកសាងសន្តិភាពនៅកម្ពុជា ការដោះស្រាយជម្លោះ និងបញ្ហាប្រកប ដោយប្រសិទ្ធិភាព និង សមភាពយេនឌ័រ



# សាទរ សង្គមល្អ នៅកម្ពុជា

CIPE

គាំទ្រថវិកាដោយ CIPE

SILAKA

ផ្ទះលេខ ៩៥B- ៩៥C សង្កាត់បឹងកេងកង៣ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា

ទូរស័ព្ទលេខ (៨៥៥) ២៣ ២១៧ ៨៧២ /២១០ ៩០២ ទូរស័ព្ទដៃ (៨៥៥) ១២ ៧៩ ២៣ ៧៩

E-mail: silaka@silaka.org; / Website: www.silaka.org